ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៦៩ ត្រីមាសទី០៣ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន
ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨១៩ ស្តីពី ការតែងតាំងមុខតំណែងជាអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ២រូប | ៨៥០១ |
| ៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨២០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **លែវ ជៅវយៀន** (LIAO JIAOYAN) ជនជាតិចិន សញ្ជាតិចិន | ៨៥០២ |
| ៧-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨២១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចាង យៀនផឹង** (ZHANG YANPENG) ជនជាតិចិន សញ្ជាតិចិន | ៨៥០៣ |
| ៨-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨២២ ស្តីពី ការផ្តល់គោរមងារ ឧកញ៉ា **ទ្រី ភាព** និងលោកជំទាវឧកញ៉ា **គៀន ស្រីនាង** ជា អ្នកឧកញ៉ា | ៨៥០៤ |
| ៨-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ១ រូប និងក្រសួងការពារជាតិចិន និងក្រសួងការពារប្រទេសវៀតណាម | ៨៥០៥ |
| ៨-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨២៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១៧ រូប | ៨៥០៦ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ១៥-១១-២០២១ | -អនុក្រឹត្យលេខ ២២៤ អនក្រ.បក ស្តីពី ការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម | ៨៥០៨ |
| ១៥-១១-២០២១ | -អនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៨៥១២ |
| ១៥-១១-២០២១ | -អនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពី ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា | ៨៥១៤ |
| ១-១២-២០២១ | -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | ៨៥៣២ |
| ១-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទានកម្ពុជា | ៨៥៣៤ |
| ១-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៨៥៣៦ |
| ៣-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ | ៨៥៣៧ |
| ៧-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ | ៨៥៣៨ |

| | | |
|---|---|---|
| ៨-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៧ អនក្រ.បក ស្ដីពី ការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ | ៨៥៤០ |
| ៨-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ៨៥៤២ |
| ៨-១២-២០២១ | -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ៨៥៤៤ |
| ៨-១២-២០២១ | -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៨៥៤៦ |
| ៨-១២-២០២១ | -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ៨៥៤៧ |

## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| | | |
|---|---|---|
| ១៣-៨-២០២១ | -ប្រកាសអន្តរក្រសួងលេខ ៥០០ សហវ.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពី ការគ្រប់គ្រងថវិកា និងធនធានសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ | ៨៥៤៨ |
| ១៨-៨-២០២១ | -ប្រកាសលេខ ៥០៧ សហវ.ប្រក ស្ដីពី ការបង្កើត និងដាក់ឱ្យដំណើរការការិយាល័យគយ និង រដ្ឋាករមួយចំនួនតាមបណ្ដាខណ្ឌនានានៃរាជធានីភ្នំពេញ | ៨៥៥១ |
| ៨-៩-២០២១ | -ប្រកាសលេខ ៥៣៧ សហវ.ប្រក ស្ដីពី ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ របស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | ៨៥៥៤ |
| ៨-៩-២០២១ | -ប្រកាសលេខ ៥៤០ សហវ.ប្រក ស្ដីពី ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ របស់និយ័តករបរធនបាលកិច្ច | ៨៥៦០ |

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| | | |
|---|---|---|
| ២-៩-២០២១ | -ប្រកាសលេខ ៣០៨ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សិន វ៉ាង យីង ញូ មេធៀរៀល ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង | ៨៥៦៦ |
| ២-៩-២០២១ | -ប្រកាសលេខ ៣០៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សេនយ៉ុន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់ | ៨៥៦៩ |
| ២-៩-២០២១ | -ប្រកាសលេខ ៣១០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ្រេស គ្លរី (ខេមបូឌា) ហ្គាម៉ិន បង្កើតរោងចក្រ កាត់ដេរ និងបោះពុម្ពសម្លៀកបំពាក់ | ៨៥៧២ |
| ៣-៩-២០២១ | -ប្រកាសលេខ ៣១១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉េដ គ្លូប៊ល អឹភែរឹល ឯ.កបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨៥៧៥ |
| ៣-៩-២០២១ | -ប្រកាសលេខ ៣១២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ វ៉ាយដ៍ អឹភែរឹល ឯ.ក បង្កើតរោងចក្រ កាត់ដេរ ចាក់សម្លៀកបំពាក់ និងផលិតម៉ាស | ៨៥៧៨ |

### ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

| | | |
|---|---|---|
| ៣-១១-២០២០ | -ប្រកាសលេខ ០៤៩៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៤៩៥ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ | ៨៥៨១ |

២៤-១១-២០២០ -ប្រកាសលេខ ០៥៣៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៣៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨៥៨៥

២៤-១១-២០២០ -ប្រកាសលេខ ០៥៦០ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥៦០ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨៥៨៩

២៤-១១-២០២០ -ប្រកាសលេខ ០៥៦២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥៦២ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨៥៩៣

២៤-១១-២០២០ -ប្រកាសលេខ ០៥៦៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៦៥ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨៥៩៧

២៥-១១-២០២០ -ប្រកាសលេខ ០៥៩៣ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥៩៣ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨៦០១

៤-១២-២០២០ -ប្រកាសលេខ ០៦១៦ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦១៦ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០ ៨៦០៥

៤-១២-២០២០ -ប្រកាសលេខ ០៦១៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦១៨ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០ ៨៦០៩

៤-១២-២០២០ -ប្រកាសលេខ ០៦២២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦២២ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០២០ ៨៦១៣

៧-១២-២០២០ -ប្រកាសលេខ ០៦២៣ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦២៣ រថ.អប្រក.លអ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២០ ៨៦១៧

៧-១២-២០២០ -ប្រកាសលេខ ០៦២៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦២៤ រថ.អប្រក.លអ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២០ ៨៦២១

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៨១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងជាអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ០២រូប ៖

១. ឯកឧត្តម **សូ សុខ**
២. ឯកឧត្តម **តូច ម៉ាម៉ូរី**

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពារ៧.២២១២.៨៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបង្គំក្រាបបង្គំទូលថ្វាយ
ឱ្យឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

ជូនចំពោះព្រះបាទ... 

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **លែវ ជៃវយៀន** (LIAO JIAOYAN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពារក.២០២១.៥៣៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ញាតិខ្មែរ ដោយសញ្ញាតូបនីយកម្មដល់អ្នកស្រី **ចាង យៀនផឹង** (ZHANG YANPENG) ជនជាតិ ចិន សញ្ញាតិ ចិន កើតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩១ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរជ.២១១២.៥៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៤២២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

១- ឧកញ៉ា **ទ្រី ភាព**
២- លោកជំទាវឧកញ៉ា **គៀន ស្រីនាង**

ជា

**អ្នកឧកញ៉ា**

នរោត្តម សីហមុនី

តរស.២១១២.៤២០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៤៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

ក. គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** :

១-ក្រសួងការពារជាតិចិន Ministry of National Defence of China

២-ក្រសួងការពារប្រទេសវៀតណាម Ministry of National Defence of Vietnam

ខ. គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

-Mr. SUPACHAI VERAPUCHONG

នរោត្តម សីហមុនី

ពរស.៥១១៤.៩៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩២៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

**ក.គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធិ :**

-វរសេនីយ៍ឯក ខេង សារុធ អត្តលេខ០០៨៥៨៣

**ខ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-វរសេនីយ៍ទោ ប្រាក់ សេរីរដ្ឋា អត្តលេខ១៦៤៥២៨
២-វរសេនីយ៍ទោ មាស បញ្ញារុធ អត្តលេខ២៤០២៤៦

**គ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-វរសេនីយ៍ឯក អ៊ិច កងដែនឧភា អត្តលេខ១៩៨៦៩២
២-វរសេនីយ៍ទោ ភាព តុលា អត្តលេខ២៣៩៨៥៤

**ឃ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-ឧត្តមសេនីយ៍ត្រី ឡុក ឡេងហួន អត្តលេខ០៤៣៥២១
២-វរសេនីយ៍ទោ រេន ប៊ុនឡេង អត្តលេខ២០៨៤៨៨

**ង.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-វរសេនីយ៍ឯក ម៉ិញ សារ៉ន អត្តលេខ០១៩១៨៧
២-វរសេនីយ៍ឯក ង៉ែត នរិន្ទ្ររដ្ឋនី អត្តលេខ០៦៧៧០៧
៣-វរសេនីយ៍ទោ ព្រាប ពិសិដ្ឋ អត្តលេខ០៥៨៨៩៤
៤-វរសេនីយ៍ទោ ទូន ប៊ិចវុទ្ធី អត្តលេខ១៦៤៥៩៦
៥-វរសេនីយ៍ទោ ជា គឹមហួរ អត្តលេខ១៩៨៨៥០
៦-វរសេនីយ៍ទោ ហែម សុវណ្ណជា អត្តលេខ២៣០១៨៤
៧-វរសេនីយ៍ទោ សេក កុសល អត្តលេខ២៣៩១១២
៨-វរសេនីយ៍ត្រី យ៉ាវ ដារ៉ា អត្តលេខ១៦៥៦៥០
៩-អនុសេនីយ៍ត្រី ហួត ណាងហរ អត្តលេខ២៤៩០០១

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១០-នាយចំណង់ ហ៊ាប តាំងគីម អត្តលេខ២៤៩០០២

នរោត្តម សីហមុនី

ការល. ២០១៤. ៥៤២

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈ-កម្មាធិការប្រតិបត្តិនិងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- បានឃើញអនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាបំណោះទូទៅ
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនុក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត "**មូលនិធិហិរញ្ញប្បទានគាំពារសង្គម**" សរសេរជាអក្សរកាត់ **ម.គ.ស.** ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញប្បទានប្រព័ន្ធគាំពារសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

**ម.គ.ស.** មានវិសាលភាពអនុវត្តចំពោះរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គម មានជាអាទិ៍៖

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងករណីបន្ទាន់ និងកម្មវិធីជាតិជំនួយសង្គមផ្សេងៗទៀត ក្នុងក្របខណ្ឌកញ្ចប់ កម្មវិធីគ្រួសារ
- កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករ-និយោជិតជាស្ត្រី នៅពេលសម្រាលកូន
- ប្រព័ន្ធកំណត់អត្តសញ្ញាណប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋគោលដៅសម្រាប់កម្មវិធីជាតិ និងរបបក្នុងប្រព័ន្ធគាំពារសង្គម
- កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមផ្សេងទៀត តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី២

## ប្រភពធនធាន

**មាត្រា៣.-**

**ម.គ.ស.** មានប្រភពធនធានពី៖

- វិភាគទានដំបូងរបស់រដ្ឋ
- ថវិការដ្ឋដែលវិភាជប្រចាំឆ្នាំសម្រាប់ហិរញ្ញប្បទានកម្មវិធីជាតិ និងរបប ដូចមានចែងក្នុងមាត្រា២
- ហិរញ្ញប្បទានសហប្រតិបត្តិការ និងហិរញ្ញប្បទានពីប្រភពស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៣
## ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងមូលនិធិ

**មាត្រា៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលខុសត្រូវក្នុងការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង **ម.គ.ស.** ដោយមានប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមបំពេញតួនាទីជាលេខាធិការដ្ឋាន។

**មាត្រា៥.-**

ធនធានហិរញ្ញវត្ថុរបស់ **ម.គ.ស.** ត្រូវរក្សាទុកក្នុងគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ឬគណនីនៅធនាគារជាតិនៃកម្ពុជា។ **ម.គ.ស.** អាចមានគណនីនៅធនាគារពាណិជ្ជ ដើម្បីប្រើប្រាស់ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៤
## ការរៀបចំ និងការអនុវត្តថវិកាប្រចាំឆ្នាំ

**មាត្រា៦.-**

កញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដូចមានកំណត់ក្នុងមាត្រា២ ត្រូវគ្រោងក្នុងក្របខណ្ឌកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ។

ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ត្រូវរៀបចំកម្មវិធីឧបត្ថម្ភប្រាក់សម្រាប់បើកផ្តល់តាមកម្មវិធីចំណាយ និងស្របតាមឥណទានថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ទៅតាមតម្រូវការចំណាយជាក់ស្តែង ដើម្បីរក្សាទុកក្នុងគណនីប្រាក់បញ្ញើរបស់ **ម.គ.ស.**។

**ម.គ.ស.** ត្រូវគ្រប់គ្រងកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម និងចាត់ចែងបើកផ្តល់សម្រាប់ការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ទៅតាមសំណើរបស់ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្ត ។

**មាត្រា៧.-**

នីតិវិធីអនុវត្តថវិកាប្រចាំឆ្នាំសម្រាប់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៥ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២១០ លានរៀល (ពីររយដប់លានរៀលគត់) ពីជំពូក ៦១ (សេវាកម្ម) មកបំពេញក្នុងជំពូក ៦០ (ការទិញ) ជូនអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បន្តនិរន្តរភាពការងារអាទិភាពនិងដំណើរការរដ្ឋបាល ក្នុងឆ្នាំ ២០២១។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១១កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១២៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតឯកសណ្ឋានគោរមងារផ្លូវការជូនអ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ ._**

ឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក របស់អ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានប្រើប្រាស់ក្នុងពេលចូលរួមពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា ៣ ._**

ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា និងឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្លៀកពាក់ទៅតាមគោរមងារដែលទទួលបានជា អ្នកឧកញ៉ា និងឧកញ៉ា ។

### ផ្នែកទី១

### ឯកសណ្ឋានគោរមងារ អ្នកឧកញ៉ា

**មាត្រា ៤ ._**

ឯកសណ្ឋានគោរមងារផ្លូវការរបស់អ្នកឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ុលបកបិតទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាងមិនជីបស្មា ជីបខ្នង និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំពីរ និងមានទំហំ២៤មីលីម៉ែត្រ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានរូបព្រះរាជសង្ហារពណ៌មាសទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧ ។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារអ្នកឧកញ៉ា** ដូចមានចែងក្នុងចំណុច **ក** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-ខោ ៖** ជើងវែងពណ៌សដូចពណ៌អាវ ដេរច្នៃរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ។ ហោប៉ៅខាងក្រោយដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌ខោ ។

**ឃ-ខ្សែក្រវ៉ាត់ ៖** ខ្សែក្រវ៉ាត់ធ្វើអំពីស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ធ្វើអំពីមាស ដែលមានរូបសញ្ញាជាអក្សរកាត់(**អ.ឧ**) អមដោយក្បាច់ភ្ញីវល្លិ៍ និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ។

**ង-ស្បែកជើង ៖** ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់ ៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១)។

**២-ចំពោះស្ត្រី**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ដូចបុរសដែរ ប៉ុន្តែមានជីបរាងចំហោប៉ៅខាងលើចុះក្រោម តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោម ខិតចំហៀងចំចង្កេះទាំងសងខាងដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧ ។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរពងារអ្នកឧកញ៉ា** ដូចមានចែងក្នុងចំណុច **ក** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-សំពត់បត់ជាមួង៖** ពណ៌បៃតងចាស់ មានសំរុងត្រឹមភ្នែកជើង សម្រាប់ប្រើជាមួយអាវកុត កត្រង់ ដៃវែង ពណ៌ស ។

**ឃ-ស្បែកជើង៖** ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់ ៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២) ។

## ផ្នែកទី២

## ឯកសណ្ឋានគោរមងារ ឧកញ៉ា

**មាត្រា ៥.―**

ឯកសណ្ឋានគោរមងារផ្លូវការរបស់ឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៉ូលបកបិតទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាងមិនជីបស្មា ជីបខ្នង និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំពីរ និងមានទំហំ២៤មីលីម៉ែត្រ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានរូបព្រះរាជសង្ហារពណ៌មាសទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារឧកញ៉ា** ដូចមានចែងក្នុងចំណុច **ខ** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-ខោ ៖** ជើងវែងពណ៌សដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ។ ហោប៉ៅខាងក្រោយដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌ខោ ។

**ឃ-ខ្សែក្រវ៉ាត់ ៖** ខ្សែក្រវ៉ាត់ធ្វើអំពីស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ធ្វើអំពីមាស ដែលមានរូបសញ្ញាជាអក្សរកាត់ (ឧ) អមដោយក្បាច់ភ្ញីវល្លិ៍ និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ។



ហ្វ

**ង-ស្បែកជើង ៖** ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៣)។

២-ចំពោះស្ត្រី

**ក-អាវ ៖**

- អាវកុត កត្រង់ ដៃវែងពណ៌ស មានប៊ូលបកបិតទាំងសងខាង ដូចបុរសដែរ ប៉ុន្តែមានជីបរាងចំហោប៉ៅខាងលើចុះក្រោម តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបព្រះរាជសង្ហារពណ៌មាសចំនួនប្រាំ ។ អាវនេះ មានហោប៉ៅខាងមុខដេរបង្កប់ចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ១៨មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ទំហំ២១មីលីម៉ែត្រ ។
- នៅលើស្មាទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិស្មា** ដូចមានចែងក្នុងចំណុច១ នៃមាត្រា៧ ។
- ចុង កអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងកអាវ** ដូចមានចែងក្នុងចំណុច២ នៃមាត្រា៧។
- នៅចុង ដៃអាវទាំងសងខាង មានបំពាក់**សញ្ញាស័ក្តិលើចុងដៃអាវ** ដូចមានចែងក្នុងចំណុច៣ នៃមាត្រា៧ ។
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់**មេដាយគោរមងារឧកញ៉ា** ដូចមានចែងក្នុងចំណុច **គ** នៃមាត្រា៨ ។

**ខ-បន្តោងខ្សែក ៖** នៅខាងក្រោមសញ្ញាស័ក្តិលើចុងកអាវ មានបំពាក់**បន្តោងខ្សែកមាស** ត្រឹមដើមទ្រូង ដូចមានចែងក្នុងមាត្រា៩ ។

**គ-សំពត់បត់ជាមួង ៖** ពណ៌បៃតងចាស់ មានសំរុងត្រឹមភ្នែកជើង សម្រាប់ប្រើជាមួយអាវកុត កត្រង់ ដៃវែង ពណ៌ស ។

**ឃ-ស្បែកជើង ៖** ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់ ៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ (ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៤) ។

## ជំពូកទី៣
## សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក

**មាត្រា ៦ .—**

សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានប្រើប្រាស់ទៅតាមអតីតភាព នៃការទទួលបានគោរមងារនីមួយៗ ។



ស៊

## ផ្នែកទី១
## សញ្ញាស័ក្តិ

**មាត្រា ៧ ._**

សញ្ញាស័ក្តិសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា រួមមាន សញ្ញាស័ក្តិស្មា សញ្ញាស័ក្តិចុងកអាវ និងសញ្ញាស័ក្តិចុងដៃអាវ ។

**១-សញ្ញាស័ក្តិស្មា ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៦.២សង់ទីម៉ែត្រ គុណនឹង ១៣.២សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌មាស (**អ.ឧ**)សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** លំអដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។

**២-សញ្ញាស័ក្តិចុងកអាវ ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៤សង់ទីម៉ែត្រ គុណនឹង ៨សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌មាស (**អ.ឧ**)សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** លំអរដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។

**៣-សញ្ញាស័ក្តិចុងដៃអាវ ៖** មានផ្ទៃពណ៌បៃតងចាស់ ទំហំ៩.៨សង់ទីម៉ែត្រ គុណនឹង ៣២សង់ទីម៉ែត្រ លំអដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងមានខ្សែរឹមពណ៌មាសនៅអមជុំវិញ ។ រីឯសញ្ញាស័ក្តិចុងដៃអាវ សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** មានខ្សែរឹមពណ៌មាសព័ទ្ធពីរជាន់លើក្បាច់ភ្ញីវល្លិ៍ពណ៌មាស ។

## ផ្នែកទី២
## មេដាយ

**មាត្រា ៨ ._**

មេដាយសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា មានបីប្រភេទ ៖

**ក-មេដាយមាស ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ធ្វើអំពីមាស(**អ.ឧ**) សម្រាប់សម្គាល់គោរមងារ**អ្នកឧកញ៉ា** និង(**ឧ**)សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ។ មេដាយនេះប្រើសម្រាប់អ្នកមានគោរមងារ**ឧកញ៉ា** ដែលមានអតីតភាពចាប់ពី១០ឆ្នាំឡើងទៅ ។ ដោយឡែកចំពោះគោរមងារ**អ្នកឧកញ៉ា** ត្រូវប្រើប្រាស់មេដាយនេះទាំងអស់ ដោយពុំមានកំណត់អតីតភាពនោះទេ ។

**ខ-មេដាយប្រាក់ ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ធ្វើអំពីប្រាក់(**ឧ**) សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ដែលមានអតីតភាពចាប់ពី០៥ឆ្នាំ ដល់១០ឆ្នាំ ។

**គ-មេដាយសំរឹទ្ធ ៖ មានរាងស្លឹកពោធិ៍បញ្ឈរ** លំអដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ ទំហំ ៥.២សង់ទីម៉ែត្រ គុណនឹង ៦.៧សង់ទីម៉ែត្រ មានរូបសញ្ញាជាអក្សរកាត់ពណ៌សំរឹទ្ធ(**ឧ**) សម្រាប់សម្គាល់គោរមងារ**ឧកញ៉ា** ដែលមានអតីតភាពក្រោម០៥ឆ្នាំ ។

## ផ្នែកទី៣

## បន្ទោខខ្សែក

**មាត្រា ៩ ._**

បន្តោងខ្សែកសម្រាប់ពាក់លើឯកសណ្ឋានគោរមងារផ្លូវការ អ្នកឧកញ៉ា និងឧកញ៉ា គឺប្រើបន្តោងខ្សែកមាស មានរាងស្លឹកពោធិ៍សំយុងចុះ និងផ្នែកខាងចុងរាងបត់ទៅខាងស្តាំបន្តិច លំអរដោយក្បាច់ពងត្រី និងក្បាច់កញ្ចាំងព័ទ្ធជុំវិញ មានទំហំ៦.៩សង់ទីម៉ែត្រ គុណនឹង ៩សង់ទីម៉ែត្រទាំងអស់គ្នា។ បន្តោងខ្សែកសម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា មានរូបសញ្ញាអក្សរកាត់(អ.ឧ) និងសម្រាប់ពាក់លើឯកសណ្ឋានគោរមងារឧកញ៉ា មានរូបសញ្ញាអក្សរកាត់(ឧ) ។

## ជំពូកទី៤

## ផ្នែកទី១

## ការផ្តល់

**មាត្រា ១០ ._**

ឯកសណ្ឋានគោរមងារផ្លូវការ សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវបានពិនិត្យ រៀបចំ និងផ្តល់ជូនតាមគោលការណ៍កំណត់របស់សមាគមមូលនិធិសម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ។

## ផ្នែកទី២

## ការប្រើប្រាស់ឯកសណ្ឋាន

**មាត្រា ១១ ._**

ឯកសណ្ឋានគោរមងារផ្លូវការ អ្នកឧកញ៉ា និងឧកញ៉ាទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងជាប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកសមាគមមូលនិធិ សម្តេចតេជោ ដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា សម្រាប់ប្រើប្រាស់ក្នុងពេលចូលរួមក្នុងពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា ១២ ._**

ជនណាដែលបានប្រើប្រាស់ ឬក្លែងបន្លំឯកសណ្ឋានគោរមងារផ្លូវការ សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់ពាក់លើឯកសណ្ឋានគោរមងារអ្នកឧកញ៉ា និងឧកញ៉ា ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១១កើត ខែ កត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

## នៃអនុក្រឹត្យលេខ ...១២៦ អនក្រ.បក.......... ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា**

**១.ចំពោះ បុរស**

**អាវកុត ក្រវាត់ និងខោ**

ពីមុខ



ពីក្រោយ



ខ្សែក្រវ៉ាត់បុរស



ស្បែកជើងបុរស



ពីមុខ



ពីក្រោយ



ស្រោមជើងបុរស



# ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក............ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា

**២. ចំពោះ ស្ត្រី**

**អាវកុត ក្រវ៉ាត់ និងសំពត់ផាមួង**

ពីមុខ



ពីក្រោយ



ស្បែកជើងស្ត្រី



ពីមុខ



ពីក្រោយ



ស្រោមជើងស្ត្រី



# ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ..២២៦..អនក្រ.បក.......... ចុះថ្ងៃទី.១៥.ខែវិច្ឆិកា.ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារឧកញ៉ា

**១.ចំពោះ បុរស**

### អាវកុត កត្រង់ និងខោ

ពីមុខ



ពីក្រោយ



ខ្សែក្រវ៉ាត់បុរស



ស្បែកជើងបុរស



ពីមុខ



ពីក្រោយ



ស្រោមជើងបុរស



# ឧបសម្ព័ន្ធទី ៤

នៃអនុក្រឹត្យលេខ...២២៦..អនក្រ..បក.......... ចុះថ្ងៃទី.១៥..ខែ.វិច្ឆិកា..ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្ទោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារឧកញ៉ា**



**២. ចំពោះ ស្ត្រី**

**អាវកុត ក្រវ៉ាត់ និងសំពត់ផាមួង**

ពីមុខ



ពីក្រោយ



ស្បែកជើងស្ត្រី



ពីមុខ



ពីក្រោយ



ស្រោមជើងស្ត្រី



# ឧបសម្ព័ន្ធទី ៥

នៃអនុក្រឹត្យលេខ.២២២៦.អនក្រ.បក.ចុះថ្ងៃទី..១៥..ខែ..វិច្ឆិកា....ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ បន្តោងខ្សែក និងខ្សែក្រវ៉ាត់ សម្រាប់គោរមងាផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូសញ្ញាស័ក្តិ មេដាយ បន្តោងខ្សែក និងខ្សែក្រវ៉ាត់សម្រាប់អ្នកឧកញ៉ា



មេដាយ



បន្តោងខ្សែក



ស័ក្តិលើស្មា



ស័ក្តិលើ កអាវ



ស័ក្តិចុងដៃអាវ



ក្បាលខ្សែក្រវ៉ាត់

## ឧបសម្ព័ន្ធទី ៦

នៃអនុក្រឹត្យលេខ២២៦.អនក្រ.បក ចុះថ្ងៃទី.១៥...ខែវិច្ឆិកា.....ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ បន្ទោងខ្សែក និងខ្សែក្រវ៉ាត់ សម្រាប់គោរមងាររផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូសញ្ញាស័ក្តិ មេដាយ បន្ទោងខ្សែក និងខ្សែក្រវ៉ាត់សម្រាប់**
**ឧកញ៉ា**





មេដាយ



បន្ទោងខ្សែក



ស័ក្តិលើស្មា



ស័ក្តិលើ កអាវ



ស័ក្តិចុងដៃអាវ





ក្បាលខ្សែក្រវ៉ាត់

# ឧបសម្ព័ន្ធទី ៧

នៃអនុក្រឹត្យលេខ...២២៦...អនក្រ.បក.......... ចុះថ្ងៃទី.១៥.ខែវិច្ឆិកា.ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា**



# ឧបសម្ព័ន្ធទី ៨

នៃអនុក្រឹត្យលេខ...២២៦ អនក្រ.បក......... ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ
របស់អ្នកឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

## គំរូឯកសណ្ឋានគោរមងារអ្នកឧកញ៉ា



# ឧបសម្ព័ន្ធទី ៩

## នៃអនុក្រឹត្យលេខ...១២២៦ អនក្រ.បក......... ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
## ស្ដីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរមងារផ្លូវការ របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរមងារឧកញ៉ា**



# ឧបសម្ព័ន្ធទី ១០

នៃអនុក្រឹត្យលេខ....២២៦.អនក្រ.បក........ ចុះថ្ងៃទី.១៥ ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីឯកសណ្ឋាន សញ្ញាស័ក្តិ មេដាយ និងបន្តោងខ្សែក សម្រាប់គោរពងារផ្លូវការ
របស់ឧកញ៉ា នៃព្រះរាជាណាចក្រកម្ពុជា

**គំរូឯកសណ្ឋានគោរពងារឧកញ៉ា**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ សម្រាប់អាណត្តិឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ដែលមានរាយនាមដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ស សុខា** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២- | ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣- | ឯកឧត្តម **ឡៅ ហ៊ិម** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- | លោកបណ្ឌិត **សរ ចិត្រា** | អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- | ឯកឧត្តម **សួន សុម៉ាលីន** | អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ៦- | ឯកឧត្តមបណ្ឌិត **សិត ខន** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ជាស៊ីម កំចាយមារ | សមាជិក។ |

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ១២[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ [illegible] ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បកចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី០៦ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩២៦ អនក្រ.តត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញលក្ខន្តិកៈសាជីវកម្មធានាឥណទានកម្ពុជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងលោក គីម សម្បត្តិ អនុប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទាន-កម្ពុជា ជំនួសលោកស្រី ឃី ស្រីស្រស់ ដែលបានផ្ទេរក្របខណ្ឌមន្ត្រីរាជការ ទៅក្រសួងមុខងារសាធារណៈ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គនាយកសាជីវកម្មធានាឥណទានកម្ពុជា និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧ ១២រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា១.** -បំពាក់មេដាយ**ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ៥រូប ដែលបានជួយឧបត្ថម្ភថវិកា និងសម្ភារៈដល់កម្លាំងការពារព្រំដែនគោក និងការិយាល័យការពារព្រំដែន នៃបញ្ជាការដ្ឋានកងទ័ពជើងគោក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**ប្រាក់ស្ថាបនាជាតិ**

១- លោកស្រី ប៊ុត សុខណា ថវិកាចំនួន ៥ ៥០០ ដុល្លារអាម៉េរិក
២- លោកស្រី ឃឿន ឡូម ថវិកាចំនួន ៥ ២០០ ដុល្លារអាម៉េរិក

ខ-មេដាយ**សំរឹទ្ធស្ថាបនាជាតិ**

១- លោកស្រី វង្ស អមរាទេវី ថវិកាចំនួន ១ ៨៨០ ដុល្លារអាម៉េរិក
២- លោកស្រី យិន សារី ថវិកាចំនួន ១ ៥០០ ដុល្លារអាម៉េរិក
៣- លោកស្រី ហ៊ុន ស៊ីនាង ថវិកាចំនួន ១ ៥០០ ដុល្លារអាម៉េរិក

**មាត្រា២.** .រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ១២ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ១១ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការលុបឈ្មោះមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** លុបឈ្មោះលោក **សំ សំណាង** ប្រធានផ្នែកលិខិតបទដ្ឋានគតិយុត្ត នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចេញពីក្របខណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១ ដោយមូលហេតុទទួលមរណភាព។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ម៉ឺល គុសល** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ២ ពីអភិបាលរង នៃគណៈអភិបាលខេត្តកំពត ឱ្យទៅបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

**មាត្រា ២ :** តែងតាំងលោក **ទិត ចន្ថនា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តកំពត។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible]ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១:** បញ្ចប់មុខតំណែងលោក **គីម សំបូរ** ពីប្រធាននាយកដ្ឋានបច្ចេកទេសនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២:** តែងតាំងលោក **ស្រួច ជុំ** ជាប្រធាននាយកដ្ឋានបច្ចេកទេសនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសលោក **គីម សំបូរ**។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហ ៦កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:**៥៥៨.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.**-បំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ចំនួន១៩គ្រឿង ជូននាយទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្រុមការងារសាងសង់សាលប្រជុំ ចំនួន១៩រូប ដែលមានស្នាដៃក្នុងការសិក្សា និងរៀបចំសាងសង់អគាររដ្ឋបាល សាលប្រជុំទីស្តីការក្រសួងការពារជាតិ សម្រេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម៖

**ក.មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ទោ | ណៃ ពុទ្ធា | អត្តលេខ១៦៥៦៣៦ | ជំនួយការ ការិយាល័យសិក្សាគម្រោង នាយកដ្ឋានវិស្វកម្ម |
| ២-វរសេនីយ៍ត្រី | ហង្ស រដ្ឋា | អត្តលេខ២៣៩៣៣៣ | ជំនួយការ ការិយាល័យស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |

**ខ.មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ត្រី | ផាន ភីរុណ | អត្តលេខ១៧០៧៩៦ | នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម |
| ២-វរសេនីយ៍ត្រី | លន់ ពិសិដ្ឋ | អត្តលេខ២៣០១៧៣ | ជំនួយការ ការិយាល័យស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ៣-អនុសេនីយ៍ឯក | ម៉ុក សុភក្តី | អត្តលេខ១៧០៧៩៧ | នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម |
| ៤-អនុសេនីយ៍ឯក | សុង សាវើយ | អត្តលេខ១៦៥៧៨១ | ជំនួយការ ការិយាល័យស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |

៥-អនុសេនីយ៍ឯក ឌុច វ៉ាន់ណារ៉ា អត្តលេខ១៧១០៩០ នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

៦-អនុសេនីយ៍ឯក នាង វណ្ណេត អត្តលេខ១៧១០៨៥ នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

៧-អនុសេនីយ៍ឯក ប៉ាវ សុធន អត្តលេខ១៧១០៩១ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

៨-អនុសេនីយ៍ឯក ឡាត់ ដាឡាន់ អត្តលេខ១៧៥០៨៨ នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

៩-អនុសេនីយ៍ឯក អួន សុភារុណ អត្តលេខ១៧១០៩២ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១០-អនុសេនីយ៍ឯក ខៀវ ចិន្តា អត្តលេខ១៧១០៨៩ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១១-អនុសេនីយ៍ទោ ឡុង សីហា អត្តលេខ១៧១០៩៤ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១២-អនុសេនីយ៍ទោ ហេង ឧត្តមរិទ្ធ អត្តលេខ១៧១០៩៥ នាយផ្នែក ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១៣-អនុសេនីយ៍ទោ ថន បូរ៉ា អត្តលេខ១៧១០៩៩ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១៤-អនុសេនីយ៍ទោ ហែម សុធីរិទ្ធិ អត្តលេខ១៧១០៩៧ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១៥-អនុសេនីយ៍ទោ ស្រ៊ុន សុងប៉ាវ អត្តលេខ១៧១០៩៣ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១៦-អនុសេនីយ៍ទោ ផាន ឆ័យ្យារ័ន អត្តលេខ១៧១០៩៨ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

១៧-អនុសេនីយ៍ទោ សឿ សុខនាង អត្តលេខ១៧១០៩៦ ជំនួយការ ការិយាល័យបច្ចេកទេសថែទាំ នាយកដ្ឋានវិស្វកម្ម

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ពុធ ៤ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៥៩ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.** -បំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគាររដ្ឋបាលថ្មី មូលដ្ឋានកងរាជអាវុធហត្ថក្រុងបាវិត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តស្វាយរៀង កន្លងមក ដូចមានរាយនាមខាងក្រោម៖

១-ឧកញ៉ា **លី ប៉ោឃ្យូ** អគ្គនាយកក្រុមហ៊ុនកាស៊ីណូពិភពថ្មី (NEW WORLD) ថវិកាចំនួន ១៥ ០០០ ដុល្លារអាម៉េរិក

២-ឧកញ៉ា **នុត វ៉ាន់នី** អគ្គនាយកក្រុមហ៊ុន P.T.S COMPANY ថវិកាចំនួន ១៤ ០០០ ដុល្លារអាម៉េរិក

៣-លោក **ចេង ប៊ុនថាំង** ប្រធានក្រុមហ៊ុន វីណា ហុងកុង ថវិកាចំនួន ២០ ០០០ ដុល្លារអាម៉េរិក

៤-លោក **ឡេង ប៉** អគ្គនាយកក្រុមហ៊ុន THE NEW YENETIAN RESORT ថវិកាចំនួន ៧០ ០០០ ដុល្លារអាម៉េរិក

| | | | |
|---|---|---|---|
| ៥-លោក | **នង សុខុម** | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តមណ្ឌលគិរី | ថវិកាចំនួន ២៥ ០០០ដុល្លារអាម៉េរិក |
| ៦-លោក | **ម៉ៅ យ៉ឹង** | ប្រធានក្រុមហ៊ុនឈាយបេតុង ក្រុងបាវិត | ថវិកាចំនួន ៣០ ០០០ ដុល្លារអាម៉េរិក<br>និងសម្ភារៈបេតុង ១៨៧ម៉ែត្រគូប |
| ៧-លោក | **ឃួន សេដ្ឋា** | អាជីវករ ក្រុងបាវិត | ថវិកាចំនួន ២០ ០០០ ដុល្លារអាម៉េរិក<br>និងសម្ភារៈថ្ម ខ្សាច់ ៤៥៦ម៉ែត្រគូប |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៦០.អនក្រ.តត.

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.**-បំពាក់ មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់**សេនា** ចំនួន០២គ្រឿង ជូនប្រធានក្រុមការងារសាងសង់ ចំនួន ០២រូប ដែលមានស្នាដៃក្នុងការរួមចំណែកសាងសង់អគារទីស្ដីការក្រសួងការពារជាតិ សម្រេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោមៈ

| | | |
|---|---|---|
| ១-Mr. | FANG JIAN | ប្រធាន ក្រុមការងារសាងសង់ (ជនជាតិចិន) |
| ២-Mrs. | PUTTIPORN SUKOSIT | ប្រធាន ក្រុមការងារសាងសង់ (ជនជាតិថៃ) |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ពុធ ៤ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៦១ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ៖** ដំឡើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណចំពោះវរសេនីយ៍ទោ **ឡុង ច័ន្ទតារា** អត្តលេខ ០៦៩៥៨ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ៤ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០០ ......សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងថវិកា និងធនធាន
សម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៧ សសរ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៨ សសរ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈប្រចាំការនៃគណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៩ សសរ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីសមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧០ សសរ. ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពនៃគណៈអនុកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ. ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ៨៣ សសរ. ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារសិក្សា និងស្រាវជ្រាវ រកឱសថ និងបរិក្ខារសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៧ សសរ. ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១០៩ សសរ. ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុកការចរចា និងការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្ត "គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងថវិកា និងធនធានសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩" ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តសម្រាប់ការគ្រប់គ្រងថវិកា និងធនធាន នៅក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រធានអនុគណៈកម្មការជំនាញក្រោមចំណុះគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.)
- យន្តការចំណុះឱ្យគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.)
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៧ សហវ.ប្រក

ប្រកាស
ស្តីពី
ការបង្កើត និងដាក់ឱ្យដំណើរការការិយាល័យគយនិងរដ្ឋាករមួយចំនួន
តាមបណ្តាខណ្ឌនានានៃរាជធានីភ្នំពេញ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៥៧៧អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៥៧៨អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៥៧៩អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ
- បានឃើញប្រកាសលេខ ៣៦២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ
- បានឃើញប្រកាសលេខ ៣៦៤ សហវ.ប្រក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករមួយចំនួនតាមបណ្ដាខណ្ឌនានានៃរាជធានីភ្នំពេញ
- បានឃើញប្រកាសលេខ ៩៣៧សហវ.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ នៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១._**

បង្កើតនិងដាក់ឱ្យដំណើរការការិយាល័យគយនិងរដ្ឋាករមួយចំនួន ដែលមានទីតាំងប្រចាំតាមបណ្ដាខណ្ឌនានា នៃរាជធានីភ្នំពេញ ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានដូចខាងក្រោម÷

១. ការិយាល័យគយនិងរដ្ឋាករខណ្ឌបឹងកេងកង

២. ការិយាល័យគយនិងរដ្ឋាករខណ្ឌកំបូល

៣. ការិយាល័យគយនិងរដ្ឋាករខណ្ឌជ្រោយចង្វារ

៤. ការិយាល័យគយនិងរដ្ឋាករខណ្ឌព្រែកព្នៅ

៥. ការិយាល័យគយនិងរដ្ឋាករខណ្ឌច្បារអំពៅ

**ប្រការ ២._**

ការិយាល័យគយនិងរដ្ឋាករនីមួយៗដូចមានចែងក្នុងប្រការ១ខាងលើ ដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យមួយចំនួនជាជំនួយការ ។

**ប្រការ ៣._**

ការិយាល័យគយនិងរដ្ឋាករនីមួយៗ តាមបណ្ដាខណ្ឌនៃរាជធានីភ្នំពេញ មានភារកិច្ចដូចតទៅ÷

១. រៀបចំ កត់ត្រា ចងក្រង និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ការិយាល័យ

២. គ្រប់គ្រងឯកសាររដ្ឋបាលចេញ-ចូលផ្សេងៗ និងបូកសរុបធ្វើរបាយការណ៍ ស្ថិតិ លទ្ធផលការងាររបស់ការិយាល័យ

៣. ចុះស្រង់ កសាងនិងកែសម្រួលបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេសរួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលគេលសិលាភេសជ្ជៈ ព្រមទាំងទំនិញសើបមួយចំនួនទៀតដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៤. ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយគ្រប់ប្រភេទដោយធ្វើអនុលោមភាពផ្ទៀងផ្ទាត់ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ខ្លួន លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬកំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន

៥. ប្រើប្រាស់កម្លាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋានជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ក្នុងករណីចាំបាច់ ដើម្បីសម្រេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ

៦. បំពេញការងារផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ៥._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ សីហា ឆ្នាំ ២០២១

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៥៣៧.....សហវ.....ប្រក

## ប្រកាស
## ស្តីពី
## ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់
## គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៦៥ អនក្រ/បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- យោងតាមការចាំបាច់សម្រាប់កិច្ចដំណើរការរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភព និងនីតិវិធីក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានានូវប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (គ.ល.ក.) អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. (អ.គ.ល.ក.) និងអង្គភាពចំណុះឱ្យ គ.ល.ក.។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ គ.ល.ក. អ.គ.ល.ក. និងអង្គភាពចំណុះឱ្យ គ.ល.ក.។

## ជំពូកទី ២

## ប្រភពធនធានហិរញ្ញវត្ថុ

**ប្រការ៣.-**

គ.ល.ក. មានប្រភពធនធានហិរញ្ញវត្ថុដូចមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។ ធនធានហិរញ្ញវត្ថុរបស់ គ.ល.ក. ត្រូវបានអនុញ្ញាតឱ្យបង់ចូលក្នុងគណនីរបស់ គ.ល.ក.។

## ជំពូកទី ៣

## ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

**ប្រការ៤.-**

ធនធានហិរញ្ញវត្ថុរបស់ គ.ល.ក. ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមគោលដៅដូចខាងក្រោម÷

- សម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់ គ.ល.ក.
- សម្រាប់គោលដៅផ្សេងទៀតតាមការណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន គ.ល.ក.។

**ប្រការ៥.-**

ធនធានសម្រាប់ទ្រទ្រង់ដំណើរការរបស់ គ.ល.ក. ត្រូវបានបែងចែកដូចខាងក្រោម÷

- ប្រាក់ឧបត្ថម្ភជីវភាព
- ប្រាក់ឧបត្ថម្ភមុខងារ
- ប្រាក់រង្វាន់សមិទ្ធកម្ម
- មូលនិធិអភិវឌ្ឍស្ថាប័ន។

**ប្រការ៦ .-**

ប្រាក់ឧបត្ថម្ភជីវភាពត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃ គ.ល.ក. ដែលមកបំពេញការងារទៀងទាត់ តាមមុខងារប្រកបដោយគុណភាពនិងផលិតភាពទៅតាមសន្ទស្សន៍និងមេគុណសមាមាត្រដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គលេខាធិការ គ.ល.ក. | ៤,00 |
| ២ | អគ្គលេខាធិការរង គ.ល.ក. | ៣,៥0 |
| ៣ | ប្រធាននាយកដ្ឋាន/ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ល.ក. | ៣,00 |
| ៤ | អនុប្រធាននាយកដ្ឋាន/អនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ល.ក. | ២,៥0 |
| ៥ | ប្រធានការិយាល័យ | ២,00 |
| ៦ | អនុប្រធានការិយាល័យ | ១,៥0 |
| ៧ | មន្ត្រី | ១,00 |

**ប្រការ៧ .-**

ប្រាក់ឧបត្ថម្ភមុខងារត្រូវបានត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃ គ.ល.ក. ដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារគោលនយោបាយ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងបទប្បញ្ញត្តិនានា ការងារចូលរួមអនុវត្តគម្រោង និងក្រុមការងារជំនាញផ្សេងៗ តាមសន្ទស្សន៍មេគុណសមាមាត្រដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គលេខាធិការ គ.ល.ក. | ៥,00 |
| ២ | អគ្គលេខាធិការរង គ.ល.ក. | ៤, 00 |
| ៣ | ប្រធាននាយកដ្ឋាន/ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ល.ក. | ៣,00 |
| ៤ | អនុប្រធាននាយកដ្ឋាន/អនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ល.ក. | ២, ៥0 |

| | | |
|---|---|---|
| ៥ | ប្រធានការិយាល័យ | ២,00 |
| ៦ | អនុប្រធានការិយាល័យ | ១,៥0 |
| ៧ | មន្ត្រី | ១,00 |

គម្រោងត្រូវមានទំហំការងារ ដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាងមួយឆ្នាំ ត្រូវតែបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាង ៣(បី)ខែ ត្រូវអនុវត្តក្នុងក្របខណ្ឌការងារប្រចាំថ្ងៃធម្មតា។

ថ្នាក់ដឹកនាំ និងមន្ត្រីនៃ គ.ល.ក. ម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបានគិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍន៍ គម្រោងមូលនិធិផ្សេងៗ ឬមន្ត្រីត្រួតពិនិត្យ ប៉ុន្តែអនុញ្ញាតឱ្យទទួលប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់ គ.ល.ក. អាចពិនិត្យ និងសម្រេចលើសំណើផ្តល់ការលើកទឹកចិត្តតាមសន្ទស្សន៍ណាមួយក្នុងចំណោមសន្ទស្សន៍ទាំង៧ ដែលបានកំណត់ខាងលើ។

**ប្រការ៨ .-**

ប្រាក់រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃ គ.ល.ក. ដែលសម្រេចបានផលលើសគោលដៅកំណត់ដូចជា ការប្រមូលចំណូលកាតព្វកិច្ចពីល្បែងពាណិជ្ជកម្មបានលើសផែនការថវិកាជាតិ ការបង្កើតឱ្យមានផលចំណេញថវិកាជាតិ ការសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ និងការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ ប្រាក់រង្វាន់សមិទ្ធកម្ម ត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅ។

**ប្រការ៩ .-**

មូលនិធិអភិវឌ្ឍស្ថាប័នត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមមុខសញ្ញាចំណាយដូចខាងក្រោម÷

១. ចំណាយចរន្ត÷ ទំនិញ សេវា និងបន្ទុកបុគ្គលិក សម្រាប់កិច្ចដំណើរការប្រចាំថ្ងៃរបស់ **អ.គ.ល.ក.** និងអង្គភាពក្រោមឱវាទ **គ.ល.ក.**។

២. ចំណាយវិនិយោគ÷ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ទីតាំងនិងអគារសម្រាប់បំពេញការងាររបស់ **គ.ល.ក.** និងការវិនិយោគផ្សេងៗសម្រាប់គ្រប់គ្រងវិស័យមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ និងល្បែងពាណិជ្ជកម្ម។

៣. ចំណាយសង្គម÷ ករណីមន្ត្រីនិងថ្នាក់ដឹកនាំជួបគ្រោះថ្នាក់ ឈឺថ្កាត់ ទទួលមរណៈភាព និងជួបគ្រោះមហន្តរាយជាដើម និងកម្មវិធីសង្គមនានា។

៤. ចំណាយផ្សេងៗ÷ ចំណាយចាំបាច់ក្រៅពីគោលដៅចំណាយខាងលើ។

## ជំពូកទី ៤
## យន្តការ និងនីតិវិធីត្រួតពិនិត្យ

**ប្រការ១០ ._**

គ.ឈ.ក. ត្រូវបង្កើត"គណៈកម្មការវាយតម្លៃសមិទ្ធកម្មមន្ត្រីនៃ គ.ឈ.ក." ដែលសរសេរជាអក្សរកាត់ថា គ.វ.ស.ម. ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មរបស់មន្ត្រីនៃ គ.ឈ.ក. សម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភ
- រៀបចំនិងស្នើឡើងនូវផែនការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីនៃ គ.ឈ.ក. ដើម្បីដាក់ជូនប្រធាន គ.ឈ.ក. ពិនិត្យ និងសម្រេច។

**ប្រការ១១ ._**

គ.វ.ស.ម. ត្រូវមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. អគ្គលេខាធិការ គ.ឈ.ក. | ប្រធាន |
| ២. អគ្គលេខាធិការរង គ.ឈ.ក. | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាន/ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ឈ.ក. | សមាជិក |
| ៤. ប្រធានការិយាល័យបុគ្គលិក | លេខាធិការ |

សមាសភាពជាក់ស្តែងនៃ គ.វ.ស.ម. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ឈ.ក.។

**ប្រការ១២ ._**

អគ្គលេខាធិការ គ.ឈ.ក. អាចបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្មរបស់នាយកដ្ឋាន និងអង្គភាពក្រោមក្រោមឱវាទ គ.ឈ.ក.។

**ប្រការ១៣ ._**

អគ្គលេខាធិការ គ.ឈ.ក. ត្រូវរៀបចំគម្រោងចំណូល-ចំណាយប្រចាំឆ្នាំរបស់ខ្លួនឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការសម្រេចពីប្រធាន គ.ឈ.ក.។

**ប្រការ១៤ ._**

អង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ឈ.ក. ត្រូវអនុវត្តសវនកម្មប្រចាំឆ្នាំដើម្បីត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មនៃការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងធនធានរបស់ គ.ឈ.ក.។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ១៥ ._**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០២២។

**ប្រការ១៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧ ._**

អគ្គលេខាធិការ អគ្គលេខាធិការរង **គ.ល.ក.** ប្រធានអង្គភាពក្រោមឱវាទ **គ.ល.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាសភាពនៃ គ.ល.ក.

"ដើម្បីជូនជ្រាប"

- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៤០ សហវ.ប្រក

# ប្រកាស
# ស្ដីពី
# ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករបរធនបាលកិច្ច

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្ដីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការចុះបញ្ជីបរធនបាលកិច្ច
- យោងតាមតម្រូវការចាំបាច់សម្រាប់ដំណើរការរបស់និយ័តករបរធនបាលកិច្ច

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone: (+855) 23 890 666

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភព និងនីតិវិធីក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានានូវប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ **ន.ប.ធ.**។

## ជំពូកទី២

## ប្រភពធនធានហិរញ្ញវត្ថុ

**ប្រការ ២.-**

**ន.ប.ធ.** មានប្រភពធនធានហិរញ្ញវត្ថុមកពី÷

- ប្រាក់វិភាគទានបង់ដោយបរធនបាលកិច្ចហិរញ្ញវត្ថុដែលបានចុះបញ្ជី សម្រាប់ទ្រទ្រង់និងអភិវឌ្ឍវិស័យបរធនបាលកិច្ច
- កម្រៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ការទទួលស្គាល់ ការចុះបញ្ជីនិងលិខិតអនុញ្ញាត សោហ៊ុយសិក្សានិងពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការទទួលស្គាល់ ការចុះបញ្ជីនិងលិខិតអនុញ្ញាត និងកម្រៃនៃការផ្តល់សេវាសាធារណៈក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ច
- កម្រៃពីការផាកពិន័យលើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច
- ប្រភពផ្សេងៗ។

## ជំពូកទី៣

## ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

**ប្រការ ៣.-**

ធនធានហិរញ្ញវត្ថុរបស់ **ន.ប.ធ.** ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមគោលដៅដូចខាងក្រោម÷

- សម្រាប់ទ្រទ្រង់ដំណើរការរបស់ **ន.ប.ធ.**
- សម្រាប់គោលដៅផ្សេងទៀតតាមការណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ៤.-**

ធនធានសម្រាប់ទ្រទ្រង់ដំណើរការរបស់ **ន.ប.ធ.** ត្រូវបានបែងចែកដូចខាងក្រោម÷

- ប្រាក់ឧបត្ថម្ភជីវភាព

- ប្រាក់ឧបត្ថម្ភមុខងារ
- ប្រាក់រង្វាន់សមិទ្ធកម្ម
- មូលនិធិអភិវឌ្ឍស្ថាប័ននិយ័តករ។

**ប្រការ ៥.-**

ប្រាក់ឧបត្ថម្ភជីវភាព ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកនៃ **ន.ប.ធ.** ដែលមកបំពេញការងារទៀងទាត់ តាមមុខងារប្រកបដោយគុណភាព និងផលិតភាព ទៅតាមសន្ទស្សន៍ និងមេគុណសមាមាត្រ ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៤,០០ |
| ២ | អគ្គនាយករង | ៣,៥០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី ឬបុគ្គលិក | ១,០០ |

**ប្រការ ៦.-**

ប្រាក់ឧបត្ថម្ភមុខងារ ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកនៃ **ន.ប.ធ.** ដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារគោលនយោបាយ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងបទប្បញ្ញត្តិនានា ការងារចូលរួមអនុវត្តគម្រោង និងក្រុមការងារជំនាញផ្សេងៗ តាមសន្ទស្សន៍មេគុណសមាមាត្រ ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៥,០០ |
| ២ | អគ្គនាយករង | ៤,០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី ឬបុគ្គលិក | ១,០០ |

គម្រោងត្រូវមានទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តតិចជាងរយៈពេល ០១ (មួយ) ឆ្នាំ ត្រូវតែបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តតិចជាងរយៈពេល ៣ (បី) ខែ ត្រូវអនុវត្តក្នុងក្របខណ្ឌការងារប្រចាំថ្ងៃធម្មតា។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបានគិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍន៍ គម្រោងមូលនិធិផ្សេងៗ និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬមន្ត្រីត្រួតពិនិត្យ ប៉ុន្តែអនុញ្ញាតឱ្យទទួលបានប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់ **ន.ប.ធ.** អាចពិនិត្យនិងសម្រេចលើសំណើផ្តល់ប្រាក់ឧបត្ថម្ភតាមសន្ទស្សន៍ណាមួយ ក្នុងចំណោមសន្ទស្សន៍ទាំង ៧ (ប្រាំពីរ) ដែលបានកំណត់ខាងលើ។

**ប្រការ ៧.-**

ប្រាក់រង្វាន់សមិទ្ធកម្ម ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិក ដែលសម្រេចបានផលលើសគោលដៅកំណត់ ដូចជា ការបង្កើតឱ្យមានផលចំណេញថវិកា ការសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ ការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ ប្រាក់រង្វាន់សមិទ្ធកម្មត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅ។

**ប្រការ ៨.-**

មូលនិធិអភិវឌ្ឍស្ថាប័ននិយ័តករ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមមុខសញ្ញាចំណាយដូចខាងក្រោម÷

១. ចំណាយចរន្ត ÷ ទំនិញ សេវា និងបន្ទុកបុគ្គលិក សម្រាប់ដំណើរការប្រចាំថ្ងៃរបស់និយ័តករ។

២. ចំណាយវិនិយោគ ÷ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ទីតាំងនិងអគារសម្រាប់បំពេញការងាររបស់និយ័តករ និងការវិនិយោគផ្សេងៗសម្រាប់អភិវឌ្ឍវិស័យបរធនបាលកិច្ច។

៣. ចំណាយសង្គម ÷ ករណីមន្ត្រីនិងថ្នាក់ដឹកនាំជួបគ្រោះថ្នាក់ ឈឺស្កាត់ ទទួលមរណៈភាព និងជួបគ្រោះមហន្តរាយជាដើម និងកម្មវិធីសង្គមនានា។

៤. ចំណាយផ្សេងៗ ÷ ចំណាយចាំបាច់ក្រៅពីគោលបំណងខាងលើ។

## ជំពូកទី៤
## យន្តការ និងនីតិវិធីត្រួតពិនិត្យ

**ប្រការ ៩.-**

**ន.ប.ធ.** ត្រូវបង្កើត "គណៈកម្មការវាយតម្លៃសមិទ្ធកម្ម" ដែលសរសេរអក្សរកាត់ថា **គ.វ.ស.** ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យនិងវាយតម្លៃសមិទ្ធកម្មរបស់មន្ត្រីនៃ **ន.ប.ធ.** សម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភ
- រៀបចំនិងស្នើឡើងនូវផែនការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីនៃ **ន.ប.ធ.** ជូនប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**ប្រការ ១០.-**

**គ.ថ.ស.** ត្រូវមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. អគ្គនាយកនៃ **ន.ប.ធ.** | ប្រធាន |
| ២. អគ្គនាយកដ្ឋានរង ១ (មួយ) រូប ឬច្រើនរូប | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាន | សមាជិក |
| ៤. ប្រធានការិយាល័យបុគ្គលិក | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.ថ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ១១.-**

អគ្គនាយកនៃ **ន.ប.ធ.** អាចបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្មរបស់នាយកដ្ឋានក្រោមឱវាទនៃ **ន.ប.ធ.**។

**ប្រការ ១២.-**

**ន.ប.ធ.** ត្រូវរៀបចំគម្រោងចំណូល ចំណាយប្រចាំឆ្នាំ ឱ្យបានច្បាស់លាស់ដើម្បីស្នើសុំការសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ១៣.-**

អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវអនុវត្តសវនកម្មប្រចាំឆ្នាំដើម្បីត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មនៃការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងធនធានរបស់ **ន.ប.ធ.**។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ១៤.-**

ប្រកាសនេះ មានអនុភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០២២។

**ប្រការ ១៥.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង

បុគ្គលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

“ដើម្បីជូនជ្រាប”

ដូចប្រការ ១៧

“ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣០៥៧ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២៤២០/២១ គ.វ.ក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់ក្រុមហ៊ុន សិន វ៉ាង យីង ញូ មេធៀរៀល ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **សិន វ៉ាង យីង ញូ មេធៀរៀល** ឯ.ក **(SEN WANG YING NEW MATERIAL CO., LTD.)** តំណាងដោយលោក **ZENG, HONGJIN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EG7318738 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ បង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង ដែលមានទីតាំងស្ថិតនៅភូមិចំបក់ផ្អែម ឃុំលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| គ្រឿងបន្សំស្បែកជើង | ១៥២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រផលិតគ្រឿងបន្សំស្បែកជើង សិន ភាង យីង ញូ មេធៀរៀល ឯ.ក**"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុតា

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកសំរោងទង
-រដ្ឋបាលឃុំរលាំងគ្រើល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣០៩......[illegible]......[illegible]......[illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...[illegible]... ខែ...[illegible]..... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- យោងលិខិតលេខ៣៧៣៧/១៧ គ.វ.ក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់ក្រុមហ៊ុន សេនយ៉ុន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន សេនយ៉ុន (ខេមបូឌា) ឯ.ក (**SENYON (CAMBODIA) CO., LTD.**) តំណាងដោយលោកស្រី **ZENG, LING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ E29344665 ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ បង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិទួលសាម៉ សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-គ្រឿងបន្សំស្បែកជើង | ១៥២០ |
| ២-គ្រឿងបន្សំសម្លៀកបំពាក់ | ១៤១០ |

